អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១១

# សេចក្តីប្រកាសព័ត៌មាន

## អង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចលើកាយសម្បទា អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ

នៅថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចលើកាយសម្បទារបស់ ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ។ នៅក្នុងសេចក្តីសម្រេចនេះ អង្គជំនុំជម្រះសាលាដំបូង បានយល់ស្របថា ជនជាប់ចោទ អៀង ធីរិទ្ធ ពុំមានកាយសម្បទា និងបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួម សវនាការ នាពេលនេះ បានទេ។ អៀង ធីរិទ្ធ ត្រូវបានរកឃើញថាមានជំងឺវង្វេងវង្វាន់ដែលកាន់តែចុះខ្សោយទៅៗ។ ដើម្បីជាផលប្រយោជន៍យុត្តិធម៌ អង្គជំនុំជម្រះសាលាដំបូងសម្រេចចិត្តជាឯកឆ្ឆ័ន្ទបំបែកបទចោទប្រកាន់ប្រឆាំងនឹង អៀង ធីរិទ្ធ និងផ្អាកកិច្ចដំណើរការនីតិវិធីចំពោះគាត់។

បើទោះបីជាមានការពិភាក្សាគ្នាអស់រយៈពេលយ៉ាងយូរក្តី និង បើទោះជាបានយល់ស្របគ្នាថា ជនជាប់ចោទពុំមានកាយសម្បទា និងបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការក្តី ក៏អង្គជំនុំជម្រះសាលាដំបូង ពុំអាចយល់ស្របគ្នាលើបញ្ហាមួយចំនួនពាក់ព័ន្ធការបន្តឃុំខ្លួនគាត់ និងលក្ខខណ្ឌនៃការដោះលែង (រួមទាំងការឃ្លាំមើល ដូចជាការបង្ខំឱ្យចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ)។ ដូចដែលអ្នកជំនាញវេជ្ជសាស្ត្រទាំងអស់បានយល់ស្របគ្នាថា អៀង ធីរិទ្ធ នឹងមិនមានអាការៈធូរស្បើយពីជំងឺ ដែលអនុញ្ញាតឱ្យគាត់អាចត្រូវជំនុំជម្រះ នាពេលអនាគត អង្គជំនុំជម្រះបានសម្រេចផ្អាកកិច្ចដំណើរការនីតិវិធីចំពោះគាត់។

ដោយសារតែគ្មានតំរុយណាមួយដែលបង្ហាញថា ជនជាប់ចោទអាចនឹងត្រូវនាំយកមកជំនុំជម្រះបាន ចៅក្រមអន្តរជាតិយល់ឃើញ ថា អ.វ.ត.ក គ្មានមូលដ្ឋានណាមួយដើម្បីបង្ខំឱ្យជនជាប់ចោទចូលព្យាបាលនៅមន្ទីរពេទ្យ ឬដាក់វិធានការបង្ខំលើរូបគាត់បានឡើយ។ ក៏ប៉ុន្តែ ចៅក្រមជាតិវិញយល់ឃើញថានៅមានលទ្ធភាពមួយចំនួនដែលគួរតែបញ្ជូនជនជាប់ចោទទៅព្យាបាលនៅមន្ទីរពេទ្យនិងដាក់គាត់ឱ្យស្ថិតនៅក្រោមវិធានការមួយចំនួន ធ្វើដូច្នេះ ទើបជនជាប់ចោទនឹងមិនអាចគេចវេសពីវង្វង់យុត្តិធម៌បាន។

ដើម្បីចៀសវាងនូវភាពមិនច្បាស់លាស់ចំពោះជនជាប់ចោទ អៀង ធីរិទ្ធ ដែលជាលទ្ធផលនៃកង្វះការព្រមព្រៀងគ្នាទៅលើការដាក់លក្ខខណ្ឌមួយចំនួននៅពេលដោះលែង អង្គជំនុំជម្រះសាលាដំបូងបានសម្រេចដោះលែងគាត់។ ដូច្នេះសេចក្តីសម្រេចដោះលែង អៀង ធីរិទ្ធពីមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក ត្រូវបានរៀបចំ។ គួរតែគូសបញ្ជាក់ថា ការរកឃើញថា អៀង ធីរិទ្ធ ពុំមានកាយសម្បទា និងបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមការជំនុំជម្រះ ពុំមានន័យថា ជាការរកឃើញថា ជនជាប់ចោទមានពិរុទ្ធភាព ឬ ភាពសុចរិតនោះទេ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃ: +៨៥៥(0)១២ ៤៨៨ 0២៣
ទូរស័ព្ទ: +៨៥៥ (0)២៣ ២១៩ ៨៤១ លេខបន្ត: ៦១៦៩
សារអេឡិចត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃ: +៨៥៥ (0)១២ ៤៨៣ ២៨៣
សារអេឡិកត្រូនិក: neth.pheaktra@eccc.gov.kh